ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ :៧២.សរ១៩....

# សារលិខិត

## សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត
## នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
## ក្នុងទិវា«ប្រជាជនពិភពលោកលើកទី៣៧» ១១ កក្កដា ឆ្នាំ២០២៦

- *សូមក្រាបថ្វាយបង្គំ សម្តេចអគ្គមហាសង្ឃរាជ សម្តេចព្រះមហាសង្ឃរាជទាំងពីរគណៈ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីគោរពសក្ការៈ!*
- *សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី !*
- *ជនរួមជាតិជាទីស្រឡាញ់រាប់អាន !*

ថ្ងៃនេះ ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំ មានសេចក្តីសោមនស្សរីករាយក្រៃលែង ដែលបានចូលរួមជាមួយប្រជាជាតិទូទាំងសកលលោក ដើម្បីប្រារព្ធ «ទិវាប្រជាជនពិភពលោកលើកទី៣៧» ក្រោមប្រធានបទដ៏មានសារៈសំខាន់គឺ **«ការសម្រេចបានក្តីសង្ឃឹម និងសេចក្តីប្រាថ្នារបស់ប្រជាជនវ័យក្មេង សម្រាប់ពេលបច្ចុប្បន្ននិងអនាគត»** (Realizing the hopes and aspirations of young people – today and futures)។ ប្រធានបទនេះមានន័យថា ការអភិវឌ្ឍប្រទេសមិនអាចកើតមានបានឡើយ ប្រសិនបើគ្មានការចូលរួមសកម្មរបស់យុវជន ដែលជាកម្លាំងចលករដ៏សំខាន់។ ក្តីសង្ឃឹមនិងសេចក្តីប្រាថ្នារបស់ពួកគេ គឺជាគន្លងដ៏សំខាន់សម្រាប់ការកសាងសង្គមប្រកបដោយសន្តិភាព សមភាព និងភាពរីកចម្រើន។ ការប្រារព្ធទិវានេះ គឺជាឱកាសដ៏មានតម្លៃសម្រាប់ព្រះរាជាណាចក្រកម្ពុជា ក្នុងការបង្ហាញពីការប្តេជ្ញាចិត្តនយោបាយកម្រិតខ្ពស់ ដើម្បីផ្តោតយុទ្ធសាស្ត្រលើកម្លាំងយុវជន ដែលជាសសរស្តម្ភទ្រទ្រង់ដ៏រឹងមាំសម្រាប់អនាគតជាតិ។

បច្ចុប្បន្ននេះ កម្ពុជាកំពុងស្ថិតក្នុងដំណាក់កាលភាគលាភប្រជាសាស្ត្រដ៏មានតម្លៃមួយ ដែលប្រជាជនវ័យក្មេង និងប្រជាជនក្នុងវ័យធ្វើការនៅតែមានចំណែកខ្ពស់។ បរិការណ៍នេះ គឺជាឱកាសដ៏សំខាន់សម្រាប់ជំរុញកំណើនសេដ្ឋកិច្ច បង្កើនផលិតភាព និងពង្រឹងមូលដ្ឋានអភិវឌ្ឍន៍រយៈពេលវែង។ ប៉ុន្តែ ភាគលាភប្រជាសាស្ត្រនេះ មិនកើតឡើងដោយស្វ័យប្រវត្តិឡើយ។ វានឹងក្លាយជាកម្លាំងជាតិពិតប្រាកដ លុះត្រាតែយើងវិនិយោគបានត្រឹមត្រូវលើមនុស្ស ជាពិសេសលើការអប់រំ ជំនាញ សុខភាព (រួមទាំងសុខភាពបន្តពូជនិងសុខភាពផ្លូវភេទ និងសុខភាពផ្លូវចិត្ត) ឱកាសការងារ សមភាពយេនឌ័រ និងបរិយាកាសសង្គម ដែលអាចអនុញ្ញាតឱ្យប្រជាជនវ័យក្មេងបង្ហាញសក្តានុពលរបស់ខ្លួនបានពេញលេញ ក្នុងការចូលរួមកសាងនិងអភិវឌ្ឍប្រទេសនៅថ្ងៃនេះ និងភាពរីកចម្រើនប្រកបដោយភាពធន់នៅថ្ងៃស្អែក។

យោងតាមរបាយការណ៍អង្កេតចន្លោះជំរឿនប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៤ ប្រជាជនកម្ពុជា មានចំនួន១៧,៣លាននាក់ ក្នុងនោះប្រជាជនវ័យក្រោម១៥ឆ្នាំ មានចំនួន២៦,៨% វ័យ១៥-៣៤ឆ្នាំ មានចំនួន៣៤,៦% វ័យ៣៥-៦៤ មានចំនួន៣២,១% និងវ័យ៦៥ឆ្នាំឡើង មានចំនួន៦,៥%។

ទិន្នន័យនេះបង្ហាញយ៉ាងច្បាស់ថា បញ្ហាប្រជាជនគឺជាបញ្ហាគន្លឹះដែលពាក់ព័ន្ធផ្ទាល់នឹងគុណភាពធនធានមនុស្ស កម្លាំងពលកម្ម ទីផ្សារការងារ ការផ្តល់សេវាសាធារណៈ សុខុមាលភាពគ្រួសារ និងសន្តិសុខសង្គមនាពេលអនាគត។ ដូច្នេះ ការរៀបចំគោលនយោបាយប្រជាជនត្រូវផ្អែកលើទិន្នន័យត្រឹមត្រូវ ទាន់ពេលវេលា និងប្រើប្រាស់បានក្នុងការសម្រេចចិត្ត ដើម្បីធានាថាការអភិវឌ្ឍរបស់កម្ពុជាមានលក្ខណៈគ្រប់ជ្រុងជ្រោយ ប្រកបដោយចីរភាព និងមិនទុកអ្នកណាម្នាក់ចោល។

ទិន្នន័យចំណោលប្រជាជនថ្មីក្នុងសេណារីយ៉ូអត្រាលទ្ធភាពមានកូនថយចុះក្នុងល្បឿនមធ្យម បង្ហាញថា ប្រជាជនកម្ពុជានឹងកើនដល់ប្រហែល ២៤លាននាក់នៅឆ្នាំ២០៥០ ក្នុងនោះប្រជាជនវ័យក្រោម១៥ឆ្នាំនឹងថយចុះដល់២១,៨% និងវ័យ១៥-៣៤ឆ្នាំនឹងថយចុះដល់២៨,២% ខណៈដែលប្រជាជនវ័យ៣៥-៦៤នឹងកើនដល់៣៧,២% និងវ័យ៦៥ឆ្នាំឡើងនឹងកើនដល់១២,៧%។ ការប្រែប្រួលរចនាសម្ព័ន្ធអាយុនេះ បញ្ជាក់យ៉ាងច្បាស់ថា ពេលវេលាដើម្បីវិនិយោគលើប្រជាជនវ័យក្មេងគឺឥឡូវនេះ។ ប្រសិនបើយើងខកខានមិនបានផ្តល់ឱកាសនិងការគាំទ្រដល់ប្រជាជនវ័យក្មេងនាពេលបច្ចុប្បន្ន យើងនឹងប្រឈមនឹងបញ្ហានានានៅពេលខាងមុខ ដូចជាការមិនទទួលបាននូវភាគលាភប្រជាសាស្ត្រទីពីរ កង្វះកម្លាំងពលកម្មជំនាញ និងការកើនឡើងនៃបន្ទុកសេដ្ឋកិច្ចនិងសង្គមដោយសារកំណើនប្រជាជនវ័យចាស់។

ការកើនឡើងនៃប្រជាជនវ័យចាស់ជាបញ្ហាមិនអាចចៀសផុតទៅថ្ងៃមុខ ក៏ប៉ុន្តែយើងត្រូវបុរេសកម្មក្នុងការរៀបចំហេដ្ឋារចនាសម្ព័ន្ធសង្គមទុកជាមុនសម្រាប់ប្រជាជនវ័យចាស់ ដើម្បីប្រែក្លាយភាពជាបន្ទុកនៃប្រជាជនវ័យចាស់ទៅជាភាគលាភប្រជាសាស្ត្រទីពីរ និងកាលានុវត្តភាពនៃការអភិវឌ្ឍសេដ្ឋកិច្ចពណ៌ប្រាក់។ នៅពេលដែលប្រជាជនវ័យក្មេងបច្ចុប្បន្នទទួលបានឱកាសការងារនិងប្រាក់ចំណូលសមរម្យ ពួកគេមិនត្រឹមតែអាចលើកកម្ពស់សេដ្ឋកិច្ចគ្រួសារនៅពេលបច្ចុប្បន្នប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានលទ្ធភាពសន្សំ និងកសាងសុវត្ថិភាពហិរញ្ញវត្ថុ សម្រាប់ធានាដល់ការរស់នៅប្រកបដោយសេចក្តីថ្លៃថ្នូរ មានលទ្ធភាពគាំទ្រកូនចៅជំនាន់ក្រោយ និងវិនិយោគបន្ត នៅពេលដែលពួកគាត់ឈានចូលវ័យចាស់។

**ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីគោរពសក្ការៈ ជនរួមជាតិទាំងអស់ជាទីស្រឡាញ់ដ៏ជ្រាលជ្រៅ!**

ក្នុងស្មារតីនេះ ខ្ញុំសូមលើកទឹកចិត្ត និងណែនាំឱ្យក្រសួង ស្ថាប័ន អាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដៃគូអភិវឌ្ឍវិស័យឯកជន សង្គមស៊ីវិល និងភាគីពាក់ព័ន្ធទាំងអស់ បន្តរួមគ្នាអនុវត្តការងារចម្បងៗ ដូចខាងក្រោម៖

**ទី១- ពង្រឹងប្រព័ន្ធទិន្នន័យប្រជាជន និងការធ្វើគោលនយោបាយផ្អែកលើភស្តុតាង៖** ការរៀបចំផែនការ និងការសម្រេចចិត្តលើវិស័យសេដ្ឋកិច្ច សង្គម អប់រំ សុខាភិបាល ការងារ និងគាំពារសង្គម ត្រូវពឹងផ្អែកលើទិន្នន័យប្រជាជនដែលមានគុណភាពខ្ពស់ ទាន់ពេលវេលា និងអាចប្រៀបធៀបបាន។ ការពង្រឹងប្រព័ន្ធស្ថិតិ ការចុះបញ្ជីអត្រានុកូលដ្ឋាន ការស្ទង់មតិ ការព្យាករប្រជាជន និងការប្រើប្រាស់ទិន្នន័យរដ្ឋបាល គឺជាមូលដ្ឋានចាំបាច់សម្រាប់រៀបចំគោលនយោបាយឱ្យចំគោលដៅនិងមានប្រសិទ្ធភាព។

**ទី២- វិនិយោគលើការអប់រំ ជំនាញ និងការងារសមរម្យសម្រាប់ប្រជាជនវ័យក្មេង៖** យុវជនកម្ពុជាត្រូវទទួលបានឱកាសស្មើភាពក្នុងការអប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈ ជំនាញឌីជីថល ស្ទែម (STEM) និងសហគ្រិនភាព និងជំនាញដែលឆ្លើយតបទៅនឹងទីផ្សារការងារថ្មី។ ការបង្កើតការងារដែលមានផលិតភាពខ្ពស់ និងការពង្រឹងទំនាក់ទំនងរវាងការអប់រំ ការបណ្តុះបណ្តាល និងតម្រូវការវិស័យឯកជន គឺជាគន្លឹះក្នុងការបម្លែងប្រជាជនវ័យក្មេងពី "ចំនួនប្រជាជន" ទៅជា "កម្លាំងអភិវឌ្ឍន៍ជាតិ"។

**ទី៣- ពង្រឹងសុខភាព សុខុមាលភាព សមភាពយេនឌ័រ និងការគាំពារក្រុមងាយរងគ្រោះ៖** ការអភិវឌ្ឍប្រជាជនប្រកបដោយចីរភាព ត្រូវការប្រជាជនដែលមានសុខភាពល្អ មានចំណេះដឹង មានសុវត្ថិភាព និងមានឱកាសស្មើគ្នា។ ដូច្នេះ ត្រូវបន្តពង្រឹងការផ្តល់សេវាសុខាភិបាល គាំពារសង្គម ការអប់រំសុខភាពគ្រួសារ ការការពារស្ត្រី កុមារ ជនមានពិការភាព និងក្រុមងាយរងគ្រោះ ដើម្បីធានាថា ការរីកចម្រើនរបស់ប្រទេសមានលក្ខណៈបរិយាបន្ន និងមានមនុស្សជាមជ្ឈមណ្ឌល។

**ទី៤- ត្រៀមខ្លួនឱ្យបានទាន់ពេលចំពោះការផ្លាស់ប្តូររចនាសម្ព័ន្ធប្រជាជន និងសង្គមវ័យចំណាស់៖** ខណៈដែលកម្ពុជាកំពុងប្រើប្រាស់ឱកាសពីប្រជាជនវ័យក្មេង យើងក៏ត្រូវរៀបចំជាមុនសម្រាប់ការកើនឡើងនៃប្រជាជនវ័យចាស់នាពេលអនាគត។ ការរៀបចំប្រព័ន្ធសុខាភិបាល ការគាំពារសង្គម សេវាថែទាំរយៈពេលវែង ប្រាក់សោធននិវត្តន៍ និងការចូលរួមរបស់មនុស្សចាស់ក្នុងសង្គម ត្រូវក្លាយជាផ្នែកមួយនៃផែនការអភិវឌ្ឍន៍រយៈពេលវែងរបស់ជាតិ។

**ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីគោរពសក្ការៈ ជនរួមជាតិទាំងអស់ជាទីស្រឡាញ់ដ៏ជ្រាលជ្រៅ!**

ជារួម ប្រធានបទនៃទិវាប្រជាជនពិភពលោកឆ្នាំនេះ រំលឹកយើងថា អនាគតរបស់កម្ពុជា នឹងត្រូវបានកំណត់ដោយគុណភាពនៃការវិនិយោគលើប្រជាជនវ័យក្មេង និងប្រជាជននៅថ្ងៃនេះ។ ប្រសិនបើយើងអាចផ្តល់ឱកាសអប់រំ សុខភាព ការងារ និងបរិយាកាសសង្គមដែលសមស្រប ប្រជាជនវ័យក្មេងកម្ពុជានឹងក្លាយជាកម្លាំងដ៏សំខាន់ក្នុងការជំរុញកម្ពុជាឱ្យសម្រេចបានចក្ខុវិស័យអភិវឌ្ឍន៍រយៈពេលវែង ក្លាយជាប្រទេសមានចំណូលខ្ពស់ និងជាសង្គមមួយដែលមានភាពធន់ប្រជាជន ប្រកបដោយសាមគ្គីភាព សមធម៌ និងចីរភាព។

ក្នុងឱកាសដ៏មានអត្ថន័យនេះ ខ្ញុំសូមអំពាវនាវដល់គ្រប់ក្រសួង ស្ថាប័ន អាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដៃគូអភិវឌ្ឍ វិស័យឯកជន សង្គមស៊ីវិល និងប្រជាពលរដ្ឋទាំងអស់ បន្តចូលរួមឱ្យបានសកម្មបន្ថែមទៀតក្នុងការលើកកម្ពស់សក្តានុពលប្រជាជនកម្ពុជា ជាពិសេសប្រជាជនវ័យក្មេង ដើម្បីធានាថាក្តីសង្ឃឹមនិងបំណងប្រាថ្នារបស់ពួកគាត់ នឹងក្លាយជាការពិតសម្រាប់ខ្លួនឯង សម្រាប់គ្រួសារ សម្រាប់សហគមន៍ សម្រាប់សង្គម និងសម្រាប់អនាគតដ៏រុងរឿងរបស់ព្រះរាជាណាចក្រកម្ពុជា។

ជាទីបញ្ចប់ ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំ សូមថ្វាយព្រះពរ ប្រគេនពរ និងជូនពរដល់សម្តេចអគ្គមហាសង្ឃរាជ សម្តេចមហាសង្ឃរាជទាំងពីរគណៈ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ព្រមទាំងបងប្អូនជនរួមជាតិទាំងអស់ សូមបានប្រកបដោយពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ថ្ងៃ សុក្រ ១១ កើត ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស. ២៥៧០

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**